ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ៣២០ សហវ.ប្រក

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការត្រួតពិនិត្យគុណភាពសវនកម្ម

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ០៨/អនក្រ/បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីសមាសភាពនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ១៨/អនក្រ/បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- យោងតាមការចំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
ទូរស័ព្ទ ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855 23 724 664 Fax: 855 23 427 798

# សម្រេច

**ប្រការ ១:-**

ត្រូវបានបង្កើត "**គណៈកម្មការត្រួតពិនិត្យគុណភាពសវនកម្ម**" ដែលហៅកាត់ថា "**គ.ត.គ.ស**" ដើម្បីធានាប្រសិទ្ធភាពនៃការអនុវត្តស្តង់ដាសវនកម្មនិងការអះអាង, ស្តង់ដាគុណភាពសវនកម្ម, និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់គណនេយ្យករជំនាញនិងសវនករប្រតិស្រុត ដើម្បីធ្វើជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១. | ឯកឧត្តម **ទី តាឃី** | ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ | ប្រធាន |
| ២. | លោក **រ័ត្ន សុវណ្ណនេះ** | តំណាងធនាគារជាតិនៃកម្ពុជា | សមាជិក |
| ៣. | លោកស្រី **នាន បូនី** | តំណាងគណៈកម្មការមូលបត្រកម្ពុជា | សមាជិក |
| ៤. | លោកស្រី **តាន់ លីនណា** | តំណាងអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ | សមាជិក |
| ៥. | លោក **រ័ត្ន មុនី** | តំណាងអគ្គនាយកដ្ឋានពន្ធដារ | សមាជិក |
| ៦. | លោក **ម៉ូ ថារិន** | តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក |
| ៧. | លោក **សេខ តុលា** | តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិក |
| ៨. | កញ្ញា **ហេង សីតា** | តំណាង វ.គ.ស.ក | សមាជិក |
| ៩. | លោក **ទ៉ែ ហ៊ុយ** | តំណាង វ.គ.ស.ក | សមាជិក |
| ១០. | កញ្ញា **តាំង យុគហ្វុង** | តំណាង វ.គ.ស.ក | សមាជិក |
| ១១. | លោក **ខាល់ ផុស** | តំណាង វ.គ.ស.ក | សមាជិក |
| ១២. | លោក **ជុង ចិត្តា** | តំណាង វ.គ.ស.ក | សមាជិក |
| ១៣. | លោកស្រី **ឡុង ស៊ីនអេនា** | តំណាង វ.គ.ស.ក | សមាជិក |
| ១៤. | លោកស្រី **សាខុន ដាលី** | តំណាងលេខាធិការដ្ឋាន វ.គ.ស.ក | សមាជិក |
| ១៥. | លោក **វ៉េង ផាត** | តំណាងក្រុមប្រឹក្សាជាតិគណនេយ្យ | សមាជិកនិងលេខាធិការ |

**គ.ត.គ.ស** អាចបង្កើតក្រុមការងារបច្ចេកទេស តាមសេចក្តីត្រូវការចាំបាច់។

**ប្រការ២:-**

**គ.ត.គ.ស** មានមុខងារនិងភារកិច្ចដូចខាងក្រោម÷

- បង្កើតគោលនយោបាយ, នីតិវិធី, បែបបទ, និងសេចក្តីណែនាំ សម្រាប់ត្រួតពិនិត្យ និងវាយតម្លៃគុណភាពសវនកម្ម និងការអះអាងរបស់សវនករប្រតិស្រុតនិងក្រុមហ៊ុនសវនកម្មក្នុងព្រះរាជាណាចក្រកម្ពុជា
- ធ្វើអធិការកិច្ចលើការអនុវត្តស្តង់ដាសវនកម្មនិងការអះអាង, ស្តង់ដាគុណភាពសវនកម្ម, និងក្រមសីលធម៌វិជ្ជាជីវៈរបស់សវនករប្រតិស្រុត និងក្រុមហ៊ុនសវនកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា

- ផ្តល់យោបល់បច្ចេកទេសលើស្តង់ដាសវនកម្មនិងការអះអាង, ស្តង់ដាគុណភាពសវនកម្ម, និងក្រម-សីលធម៌វិជ្ជាជីវៈ។

**ប្រការ ៣:-**

**គ.គ.គ.ស** ត្រូវរៀបចំប្រជុំរបស់ខ្លួន យ៉ាងហោចបួន(០៤)ដង ក្នុងមួយឆ្នាំ ដើម្បីពិនិត្យមើលវឌ្ឍនភាពនៃការអនុវត្តមុខងារនិងភារកិច្ចរបស់ខ្លួន។ កិច្ចប្រជុំ **គ.គ.គ.ស** អាចដំណើរការទៅបានលុះត្រាតែចំនួនសមាជិកវត្តមាន ច្រើនជាង ៥០ ភាគរយនៃចំនួនសមាជិកទាំងអស់។

សមាជិកនៃ **គ.គ.គ.ស** ត្រូវចូលរួមកិច្ចប្រជុំតាមការអញ្ជើញរបស់ប្រធាន។ នៅពេលប្រធានអវត្តមាន, **គ.គ.គ.ស** ត្រូវប្រជុំក្រោមការដឹកនាំរបស់សមាជិកណាមួយតាមការប្រគល់សិទ្ធិរបស់ប្រធាន ដើម្បីជានានិរន្តភាព។

សេចក្តីសម្រេចរបស់ **គ.គ.គ.ស** អាចចាត់ទុកថាជាបានការ លុះត្រាតែមានសម្លេងគាំទ្រ ២/៣ នៃសមាជិកដែលមានវត្តមាន។

ក្នុងករណីចាំបាច់ ប្រធានឬសមាជិកចំនួន ១/៣ មានសិទ្ធិស្នើសុំកោះប្រជុំវិសាមញ្ញបាន។

**ប្រការ៤:-**

សមាសភាព **គ.គ.គ.ស** ដូចមានចែងក្នុងប្រការ១ មានអាណត្តិ ០៣ ឆ្នាំ ដោយចាប់គិតចាប់ពីថ្ងៃចុះហត្ថ-លេខា នៃប្រកាសនេះ។

**គ.គ.គ.ស** ត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំ ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ.ស.គ.ស** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រុមប្រឹក្សាជាតិគណនេយ្យ។

**ប្រការ៥:-**

ថវិកាសម្រាប់ដំណើរការរបស់ **គ.គ.គ.ស** គឺជា÷

- ថវិកាជាតិរបស់ក្រុមប្រឹក្សាជាតិគណនេយ្យក្នុងក្របខ័ណ្ឌថវិកាជាតិជាឧបសម្ព័ន្ធនៃថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ថវិកាក្រោមគម្រោងរបស់ធនាគារអភិវឌ្ឍអាស៊ី និងរបស់ដៃគូអភិវឌ្ឍផ្សេងទៀត។

**គ.ស.គ.ស** អាចទទួលជំនួយឧបត្ថម្ភពីសប្បុរសជន ពីអង្គការមិនមែនរដ្ឋាភិបាលជាតិនិងអន្តជាតិ និងពីប្រភពផ្សេងៗទៀត។

**ប្រការ៦:-**

ប្រធាន និងសមាជិក នឹងត្រូវទទួលបានប្រាក់លាភការ ដែលត្រូវកំណត់ដូចក្រុមប្រឹក្សាជាតិគណនេយ្យ។

**ប្រការ៧:-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញនិងសវនករកម្ពុជា និងប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ

  " ដើម្បីគោរពជូនជ្រាប "
- ដូចប្រការ៧

  "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ